ទំនុកដំកើង១៣៨-១៣៩

# ជំពូក ១៣៨

*ប្រធានបទ បទសរសើរច្រៀងអស់ពីដួងចិត្ត*

បើយើងប្រៀបធៀបគម្ពីរទំនុកដំកើងជំពូក១៣៧ និងជំពូក១៣៨ ជំពូកទាំងពីរនេះមានអត្ថន័យ អត្ថរូប អត្ថរសខុសគ្នាដូចថ្ងៃនិងយប់។ ជំពូក១៣៧បរិយាយពីសភាពទ័លច្រកនាំអោយសាសន៍អ៊ីស្រាអែល រកច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់មិនកើត។ ជំពូក១៣៧យើងឃើញសាសន៍អ៊ីស្រាអែលព្យួរស៊ុងនៅលើដើមចាក។ គេមិនអាចសរសើរតម្កើងដល់ព្រះជាម្ចាស់បាន ពីព្រោះគេមានសេចក្តីវេទនានៅក្នុងចិត្ត ក៏ដូចជារូបកាយរបស់គេដែរ។ គេនាំគ្នាអង្គុយនៅក្បែរព្រែកជីកស្រុកបាប៊ីឡូន។ គេធ្វើការជាទម្ងន់បណ្តើរ គេនឹកស្រុកទេសរបស់គេបណ្តើរ។ ចំណែកជំពូក១៣៨វិញ យើងឃើញមានសេចក្តីទំនាយពីសេចក្តីសរសើរតម្កើងដល់ព្រះជាម្ចាស់ ដោយប្រើស៊ុងនិងពិណរបស់ខ្លួន។ នៅគ្រាអនាគត សាសន៍អ៊ីស្រាអែលនឹងនាំគ្នាច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ដោយអស់ពីចិត្ត។

គម្ពីរទំនុកដំកើងជំពូក១៣៨ ជាទំនុករបស់ព្រះបាទដាវីឌ។ យើងហ៊ានដូច្នេះពីព្រោះម្យ៉ាង យើងឃើញមានព្រះវិហារបរិសុទ្ធសម្តែងនៅក្នុងជំពូកនេះ។ វិហារនេះ

ជាត្រសាលជំនុំ។ នៅក្នុងសម័យព្រះបាទដាវីឌ តួព្រះវិហារមិនទាន់បានសង់នៅឡើយ។ សាសន៍អ៊ីស្រាអែលជួបជុំនៅជិតត្រសាលជំនុំរបស់ព្រះជាម្ចាស់ ដើម្បីថ្វាយបង្គំដល់ទ្រង់។ ម្យ៉ាងទៀត អត្ថបទក្នុងជំពូក១៣៨ មានលក្ខណៈស្រដៀងនឹងទំនុកដំកើងឯទៀតៗ ដែលព្រះបាទដាវីឌទ្រង់បានកត់ត្រាទុក។

**ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់អស់អំពីចិត្ត ទូលបង្គំនឹងច្រៀងសរសើរទ្រង់ នៅចំពោះមុខនៃអស់ទាំងព្រះ (ទំនុកដំកើង ១៣៨:១)។**

"ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់អស់អំពីចិត្ត..."។ បច្ចុប្បន្ន ជនជាតិអ៊ីស្រាអែលមិនមានសិទ្ធិចូលទៅថ្វាយបង្គំព្រះអង្គនៅកន្លែងដែលគេជឿថា ជាទីតាំងនៃព្រះវិហារបរិសុទ្ធក្នុងទីក្រុងយេរូសាឡិមទេ។ គេមានសិទ្ធិឡើងទៅត្រឹមជញ្ជាំងមួយគេហៅថា ជញ្ជាំងបោកខ្លួន។ សាសន៍អ៊ីស្រាអែលឡើងទៅថ្វាយបង្គំដល់ព្រះជាម្ចាស់ ដោយខ្លះយំបោកខ្លួន ខ្លះយកក្បាលផ្ទប់នឹងជញ្ជាំង ខ្លះស្រែកយំឡូឡា ពីព្រោះគេមានចិត្តចង់ចូលទៅក្នុងកន្លែងបរិសុទ្ធជាខ្លាំង។ ប៉ុន្តែ ការយំសោកភាគច្រើន ច្រើនតែជាប្រពៃណីរបស់សាសន៍យូដាប៉ុណ្ណោះ។ គេមិនបានយំសោកដោយអស់ពីដួងចិត្តរបស់គេទេ។ ដំណើរនេះ ប្រៀបឧបមាដូចជាគ្រីស្ទបរិស័ទបច្ចុប្បន្ននេះដែរ។ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតិចណាស់ដែលបានហៅរកព្រះអង្គ ដោយស្មោះត្រង់អស់ពីដួងចិត្ត។ ភាគ

ច្រើនហៅរកព្រះអង្គត្រឹមបបូរមាត់ប៉ុណ្ណោះ ឯចិត្តគេនៅឆ្ងាយពីព្រះអង្គខ្លាំងណាស់។ រាស្ត្ររបស់ព្រះជាម្ចាស់ទាំងសាសន៍យូដា ទាំងសាសន៍ដទៃ ត្រូវស្វែងរកព្រះអង្គដោយស្មោះត្រង់អស់ពីដួងចិត្ត។ នៅគ្រាអនាគតកាល បន្ទាប់ពីសាសន៍អ៊ីស្រាអែលសេសសល់ត្រូវឆ្លងកាត់គ្រាមហាទុក្ខ សាសន៍នេះនាំគ្នាថ្វាយបង្គំដល់ព្រះជាម្ចាស់អស់ពីដួងចិត្តរបស់ខ្លួន។ គម្ពីរនេះថែងថា "ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់អស់អំពីចិត្ត"។

ព្រះជាម្ចាស់កំពុងស្វែងរកបុគ្គល ដែលព្រមថ្វាយបង្គំព្រះអង្គដោយវិញ្ញាណនិងសេចក្ដីពិត (យ៉ូហាន៤:២៣)។ លោកអ្នកតែងធ្វើដំណើរទៅថ្វាយបង្គំដល់ព្រះជាម្ចាស់។ ការនោះជាការល្អប្រពៃហើយ។ ប៉ុន្តែ លោកអ្នកត្រូវឆ្លើយនឹងសំណួរសួរថា ពេលទៅថ្វាយបង្គំព្រះអង្គ លោកអ្នកថ្វាយបង្គំទ្រង់ដោយស្មោះត្រង់អស់ពីដួងចិត្តដែរឬ? គ្រីស្ទបរិស័ទមួយរូបនាមហូវ៉ាទីស-បូណាមានប្រសាសន៍ថា "លោកចាំបាច់ត្រូវចូលទៅថ្វាយបង្គំព្រះអង្គ ដោយប្រែចិត្តពីលក្ខណៈល្មមក្នុងចិត្តមានការផ្លាស់ប្រែ ព្រមទាំងស្គាល់ពីអំពើបាបដែលមាននៅក្នុងជីវិតរបស់លោក។ កិរិយានោះហៅថា ជាកិរិយាប្រែចិត្តចេញពីអំពើដែលលោកបានប្រែចិត្តពីមុន"។ ការប្រែចិត្តពីមុនជាកិរិយាដែលបបូរមាត់បាននិយាយថា លោកចង់ថ្វាយបង្គំព្រះជាម្ចាស់ តែកិរិយាប្រែចិត្តលើកក្រោយ ជាការបែរមករកព្រះជាម្ចាស់ដោយចិត្តទន់ទាប។ ខ្ញុំយល់ថា អ្នកជឿដល់ព្រះអង្គបច្ចុប្បន្ននេះ ចាំបាច់ត្រូវចូលទៅព្រះជាម្ចាស់នៅព្រឹកថ្ងៃច័ន្ទ ដើម្បីសូមលន់តួចំពោះព្រះអង្គ នូវកិរិយាដែលយើងបានចូលទៅថ្វាយបង្គំព្រះអង្គ ពីថ្ងៃអាទិត្យម្សិលមិញនៅក្នុងដំណាក់របស់ព្រះជាម្ចាស់។ យើងត្រូវលន់តួនៅចំពោះព្រះជាម្ចាស់ថា "ឱ

ព្រះជាម្ចាស់អើយ សូមព្រះអង្គអត់ទោសកំហុសដល់កិរិយាប្រព្រឹត្ត ដែលទូលព្រះបង្គំបានធ្វើនៅថ្ងៃអាទិត្យម្សិលមិញផង ទូលព្រះបង្គំច្រៀងសរសើរតម្កើងព្រះអង្គ តែមិនបានច្រៀងអស់ពីជម្រៅចិត្តរបស់ទូលព្រះបង្គំទេ ទូលបង្គំអធិស្ឋានស្វែងរកព្រះភក្ត្រទ្រង់ តែគ្រាន់ជាប្រពៃណីរបស់គ្រីស្ទបរិស័ទ ទូលបង្គំស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ តែមិនបានចាក់ចូលទៅក្នុងដួងចិត្តរបស់ទូលបង្គំសោះ ផ្ទុយទៅវិញ ទូលបង្គំរិះគន់គ្រូគង្វាល ទូលបង្គំរិះគន់បងប្អូនឯទៀត ទូលបង្គំមិនបានរិះគន់ខ្លួនទូលបង្គំទេ។ ដោយសារមូលហេតុនេះ សូមព្រះជាម្ចាស់អត់ទោសដល់ទូលបង្គំដែលមានអកប្បកិរិយាមិនគួរគប្បីទៅថ្វាយបង្គំព្រះអម្ចាស់ កាលពីថ្ងៃអាទិត្យម្សិលមិញនេះផងផង"។ កិរិយាទាំងអម្បាលមាណនេះ យើងចាំបាច់ត្រូវអធិស្ឋានលន់តួនៅចំពោះព្រះជាម្ចាស់នៅព្រឹកថ្ងៃច័ន្ទ។

ខមួយទៀតចែងថា "ទូលបង្គំនឹងច្រៀងសរសើរទ្រង់នៅចំពោះមុខនៃអស់ទាំងព្រះ"។ តើ "ព្រះ" ក្នុងខនេះសម្តែងពីនរណា? បណ្ឌិតម៉ាទីន-លូធ័រ និងទេវវិទូហ្វូន-កាល់វិន បានហៅ "ព្រះ" នេះថា ជាពួកទេវតា។ម្យ៉ាងទៀតអ្នកខ្លះបកស្រាយថា "ព្រះ" នេះគឺជារូបសំណាក ឬរូបព្រះដែលគេតាំងឡើងសម្រាប់ថ្វាយបង្គំជាធម្មតា។ បើតាមខ្ញុំយល់សេចក្តីសន្និដ្ឋានខាងលើត្រឹមត្រូវដែរ តែមិនទាន់ចំន័យសេចក្តីនៅឡើយ។ ពាក្យថា "អស់ទាំងព្រះ" ក្នុងខនេះ សម្តែងពីអ្វីៗទាំងអស់ដែលលោកអ្នកយកមកតាំងធ្វើជារនាំងរវាងរូបលោកអ្នក ហើយនិងព្រះជាម្ចាស់។ វត្ថុ ឬភារៈទាំងនោះជារូបព្រះសម្រាប់មនុស្សហើយ។ ត្រង់គម្ពីរទំនុកដំកើង៨២:៦ យើងឃើញថា ជនដែលព្រះជាម្ចាស់បានតាំងអោយធ្វើជាចៅក្រម ជារដ្ឋាភិបាល គ្រប់គ្រង

ប្រជាពលរដ្ឋ បានលើកខ្លួនលោកធ្វើជាព្រះជំនួសព្រះជាម្ចាស់ដែលទ្រង់បានតែងតាំងលោកអោយទទួលនាទីរក្សាសន្តិសុខនៅក្នុងសង្គម។ កិរិយាបែបនោះក៏រាប់ថាជាកិរិយា "អស់ទាំងព្រះដែរ"។ ព្រះជាម្ចាស់តែងតាំងយើងអោយធ្វើជាទូតតំណាងព្រះអង្គនៅលើលោកនេះ។ មុខនាទីរបស់យើងត្រូវបង្ហាត់បង្រៀន ផ្សាយដំណឹង និងពាំនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់នាំមនុស្សមានបាបអោយមកជានានឹងព្រះអង្គវិញ។ តើលោកអ្នកបង្ហាត់បង្រៀនព្រះបន្ទូលព្រះអង្គ ដោយរស់នៅក្នុងជីវិតបរិសុទ្ធ គាំទ្រព្រះបន្ទូលដែរឬទេ? យើងត្រូវរក្សាមុខនាទីនេះអោយបានពិតប្រាកដ។ មែនហើយយើងត្រូវទទួលស្គាល់ថា ក្នុងនាមយើងជាអ្នកបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងពិតជាមានកិរិយាខ្លះ ដែលនាំអោយគេចោទប្រកាន់ដល់យើងជាមិនខាន។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ យើងត្រូវហ៊ានសារភាពនៅចំពោះព្រះអង្គថា យើងធ្វើអស់ពីសមត្ថភាពដែលយើងអាចធ្វើបានចំពោះព្រះនេត្រព្រះអង្គ។ កិរិយានេះ ព្រះបាទដាវីឌហៅថា "ទូលបង្គំនឹងច្រៀងសរសើរទ្រង់នៅចំពោះមុខនៃអស់ទាំងព្រះ"។

> **ទូលបង្គំនឹងក្រាបថ្វាយបង្គំ ដំរង់ទៅឯព្រះវិហារបរិសុទ្ធនៃទ្រង់ ព្រមទាំងអរព្រះគុណដល់ព្រះនាមទ្រង់ផង ដោយព្រោះសេចក្តីសប្បុរស នឹងសេចក្តីពិតរបស់ទ្រង់ ដ្បិតទ្រង់បានដំកើងព្រះបន្ទូលទ្រង់ ឱ្យធំលើព្រះនាមទ្រង់ទៅទៀត (ទំនុកដំកើង១៣៨:២)។**

ខខាងលើសម្ដែងថា ព្រះបន្ទូលដែលយើងអានរៀងរាល់ថ្ងៃ មានតម្លៃស្មើនឹងអង្គព្រះជាម្ចាស់ផ្ទាល់។ សុភាសិតខ្មែរពោលថា "មនុស្សយកសម្ដី ដំរីយកភ្លុក"។ ព្រះជាម្ចាស់មានព្រះរាជបុគ្គលិកលក្ខណៈរបស់ទ្រង់ឧត្ដុង្គឧត្ដម ស្មើនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលយើងអានជាប្រចាំថ្ងៃ។ ទ្រង់មានបន្ទូលថា "ទ្រង់បានតម្កើងព្រះបន្ទូលទ្រង់អោយធំលើព្រះនាមទ្រង់ទៅទៀត"។

**ដ្បិតទោះបើព្រះយេហូវ៉ាទ្រង់ខ្ពស់ គង់តែទ្រង់យល់ដល់ពួកអ្នករាបសាដែរ តែឯមនុស្សឆ្មើងឆ្មៃ ទ្រង់ស្គាល់គេពីចំងាយហើយ (ទំនុកដំកើង១៣៨:៦)។**

ព្រះជាម្ចាស់មានភាពឧត្ដុង្គឧត្ដមខ្ពង់ខ្ពស់ដាច់ពីមនុស្សលោក ដែលអាចយល់ដល់ទ្រង់បាន។ ប៉ុន្ដែ ទោះជាយ៉ាងនោះក៏ដោយ ព្រះអង្គតែងបើកសម្ដែងអង្គទ្រង់អោយមនុស្សទន់ទាបស្វែងរកព្រះអង្គឃើញ។ នៅក្នុងព្រះបន្ទូលរបស់ទ្រង់មានសេចក្ដីជាច្រើននិយាយពីលក្ខណៈរបស់មនុស្សមានចិត្តទន់ទាប។ ជនអួតខ្លួនមិនមានចិត្តទន់ទាបទេ។ កិរិយាទន់ភ្លន់ និងកិរិយាអំនួតមានភាពផ្ទុយគ្នាដូចទិសខាងកើត និងទិសខាងលិច។ តើព្រះបន្ទូលសម្ដែងបែបណាខ្លះ ពីជនដែលមានកិរិយាទន់ទាប? គម្ពីរយ៉ាកុប ៤:៦ចែងថា "ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ"។ គម្ពីរ១ពេត្រុស៥:៦ចែងដែរថា "ដូច្នេះ ចូរឱ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោម

ព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឱ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់”។ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ ព្រមទាំងស្គាល់ចិត្តមនុស្សគ្រប់រូបដែលមានចិត្តទន់ទាបនៅចំពោះព្រះអង្គ។ ព្រះអង្គស្គាល់សន្តានចិត្តរបស់ព្រះបាទដាវីឌ។ គម្ពីរទំនុកដំកើង១៣១:១ចែងថា “ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំមិនមែនឆ្មើងឆ្មៃ ហើយភ្នែកទូលបង្គំក៏មិនប្រកាន់យស ទូលបង្គំមិនយកចិត្តទុកដាក់ក្នុងការដ៏ធំ ឬក្នុងដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ”។ គម្ពីរអេសាយ៥៧:១៥ចែងទៀតថា “ដ្បិតព្រះដ៏ជាធំ ហើយខ្ពស់បំផុត ជាព្រះដ៏គង់នៅអស់កល្បជានិច្ច ដែលព្រះនាមទ្រង់ជានាមបរិសុទ្ធ ទ្រង់មានបន្ទូលដូច្នេះថា អញនៅឯស្ថានដ៏ខ្ពស់ហើយបរិសុទ្ធ ក៏នៅជាមួយនឹងអ្នកណា ដែលមានចិត្តសង្រេង ហើយទន់ទាប ដើម្បីនឹងធ្វើឱ្យចិត្តរបស់មនុស្សទន់ទាបបានសង្ឃឹមឡើង ហើយឱ្យចិត្តមនុស្សសង្រេងបានសង្ឃឹមឡើងដែរ”។ គម្ពីរ១ពេត្រុស៥:៥ចែងថា “ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឱ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះព្រះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ”។ គម្ពីរ១ពេត្រុស៣:៤ចែងបន្ថែមទៀតថា “គឺតែងចំពោះមនុស្សលាក់កំបាំងក្នុងចិត្តវិញ ដោយគ្រឿងដ៏មិនចេះពុករលួយរបស់វិញ្ញាណសំឡូត ហើយរម្យទម នោះឯងជាសេចក្តីដែលមានដំឡៃវិសេសនៅចំពោះព្រះ”។ ខគម្ពីរដែលខ្ញុំជូនទាំងអម្បាលមាណខាងលើ សម្តែងពីព្រះជាម្ចាស់ទ្រង់យកព្រះហឫទ័យទុកដាក់នឹងមនុស្សដែលមានចិត្តទន់ទាប។

**ព្រះយេហូវ៉ា ទ្រង់នឹងធ្វើឱ្យជំនឿនរបស់ទូលបង្គំបានពេញខ្នាតឡើង ឱព្រះយេហូវ៉ាអើយ សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប សូមទ្រង់កុំបោះបង់ចោលអស់ទាំងស្នាដៃនៃព្រះហស្តទ្រង់ឡើយ (ទំនុកដំកើង១៣៨:៨)។**

ខខាងលើមានលក្ខណៈស្មើនិងខគម្ពីរភីលីព១:៦ដែលថែងថា "ខ្ញុំជឿសេចក្តីនេះជាយ៉ាងជាក់ថា ព្រះអង្គ ដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឱ្យកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ"។

# ជំពូក ១៣៩

***ចំណងជើង*** *បទសរសើរដល់ភាពឧត្តុង្គឧត្តមនៃព្រះជាម្ចាស់*

ទំនុកដំកើងជំពូក១៣៩ ជាទំនុករបស់ព្រះបាទដាវីឌ។ ជំពូកនេះបរិយាយពីភាពឧត្តុង្គឧត្តមនៃព្រះជាម្ចាស់។ ភាពឧត្តុង្គឧត្តមរបស់ទ្រង់សម្តែងអោយមនុស្សលោកឃើញក្នុងព្រះរាជបុគ្គលិកលក្ខណៈបីប្រភេទ។ មួយព្រះអង្គមានព្រះរាជបុគ្គលិកលក្ខណៈប្រកបដោយសព្វញ្ញូញ្ញាណ។ ព្រះអង្គជ្រាបអ្វីៗទាំងអស់ដែលកើតមានឡើងនៅក្នុងចិត្តរបស់មនុស្ស ក៏ដូចជានៅក្នុងពិភពលោករបស់ទ្រង់ក្នុងពេលតែមួយ។ ពីរ ទ្រង់មានព្រះរាជបុគ្គលិកលក្ខណៈប្រកបដោយសព្វវត្តមាន។ ព្រះអង្គគង់នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ។ រីឯទីបី ទ្រង់មានព្រះរាជបុគ្គលិកលក្ខណៈប្រកបដោយសព្វានុភាព។ ព្រះអង្គមានចេស្តាអាចធ្វើអ្វីបានទាំងអស់។ អ្វីៗទាំងអស់ដែលព្រះអម្ចាស់យល់ថាព្រះអង្គធ្វើសម្រាប់ជាទីតម្កើងសិរីល្អរបស់ព្រះអង្គ ទ្រង់បំពេញការនោះឥតមានអ្នកណាចាំបាច់ជួយដល់ព្រះអង្គទេ។ គេតែងតែសួរថា "បើព្រះជាម្ចាស់អាចធ្វើអ្វីបានទាំងអស់ តើព្រះអង្គធ្វើភ្នំណាមួយដែលព្រះអម្ចាស់មិនអាចលើកខ្លួនឯងរួចដែរឬទេ?" ចម្លើយគឺ ព្រះអង្គមិនដែលធ្វើអ្វីអោយគេដៀលព្រះអង្គ "ដំរិះជិះកឯង" ឡើយ។

សូមយើងពិចារណាពីព្រះរាជបុគ្គលិកលក្ខណៈ ទាំងបីប្រភេទរបស់ព្រះអង្គសម្តែងពីទ្រង់មានភាពឧត្តុង្គឧត្តមយ៉ាងខ្លាំងក្រៃលែង។

## ព្រះជាម្ចាស់ជាព្រះប្រកបដោយសព្វញ្ញូញ្ញាណ

**ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង (ទំនុកដំកើង១៣៩:១)។**

ព្រះរាជបុគ្គលិកលក្ខណៈទីមួយរបស់ព្រះជាម្ចាស់គឺ ព្រះអង្គជាព្រះដែលប្រកបដោយសព្វញ្ញូញ្ញាណ។ ព្រះអង្គជ្រាបនូវអ្វីៗទាំងអស់។ ព្រះអង្គជ្រាបពីលោកអ្នក ព្រះអង្គជ្រាបពីរូបខ្ញុំផ្ទាល់។ ព្រះជាម្ចាស់ស្គាល់ពួកហោរាសាស្ត្រគ្រប់រូប។ ពេលលោកអ្នកជួបប្រទះនឹងបញ្ហាជីវិត លោកអ្នកមិនចាំបាច់រកគ្រូហោរមកគន់គូរទេ ពោលគឺលោកអ្នកចាំបាច់ត្រូវស្វែងរកព្រះភក្ត្ររបស់ព្រះជាម្ចាស់ ដែលទ្រង់បើកសម្តែងអង្គទ្រង់តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអង្គពិតជាប្រាប់ដល់លោកអ្នកអោយស្គាល់ពីបញ្ហារបស់ជីវិតលោកអ្នកហើយ។ ពួកគ្រូហោរាសាស្ត្រមិនស្គាល់ខ្លួនឯងផង តើធ្វើដូចម្តេចអោយស្គាល់ដល់ចិត្តរបស់លោកអ្នកបាន?

**២ ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះ នឹងការដែលទូលបង្គំ**
**ក្រោកឡើងផង ទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយដែរ**
**៣ ទ្រង់ពិនិត្យពិចារណាផ្លូវច្រក នឹងទីដេករបស់ទូលបង្គំក៏ស្គាល់**
**អស់ទាំងផ្លូវប្រព្រឹត្តរបស់ទូលបង្គំដែរ ៤ ដ្បិត ឱព្រះយេហូវ៉ាអើយ**

**ពាក្យសំដីមិនទាន់មាននៅអណ្តាតទូលបង្គំនៅឡើយ នោះទ្រង់ក៏ជ្រាបគ្រប់ជំពូកហើយ (ទំនុកដំកើង១៣៩:២-៤)។**

សូម្បីពាក្យសម្តីដែលលោកអ្នកមិនទាន់គ្រលាស់អណ្តាតចេញមក នោះព្រះជាម្ចាស់ជ្រាបថា លោកអ្នកចង់និយាយពីអ្វីរួចទៅហើយ។ ឧទាហរណ៍មានពាក្យសម្តីមួយដែលលោកអ្នកហៀបនឹងនិយាយ តែបែរជាមិនហ៊ាននិយាយវិញ ដោយសារមនុស្សដែលលោកអ្នកចង់និយាយនោះ កំពុងស្ថិតនៅក្បែរលោកអ្នក។ ចំពោះមនុស្សនោះគេមិនដឹងថា លោកអ្នកកំពុងចង់និយាយពីអ្វីទេ។ ប៉ុន្តែ ចំពោះព្រះជាម្ចាស់វិញ ទ្រង់ជ្រាបពីពាក្យសម្តីដែលលោកអ្នកមិនទាន់និយាយ។ ព្រះជាម្ចាស់ជាព្រះប្រកបដោយសព្វញ្ញុតញ្ញាណ។

**៥ ទ្រង់បានព័ទ្ធទូលបង្គំជិតពីមុខពីក្រោយ ហើយបានដាក់ព្រះហស្តលើទូលបង្គំ ៦ ការដឹងច្បាស់យ៉ាងនេះ ក៏អស្ចារ្យហួសល្បត់ទូលបង្គំ ហើយខ្ពស់ដល់ម្ល៉េះ បានជាទូលបង្គំ ឈោងមិនដល់សោះ (ទំនុកដំកើង១៣៩:៥-៦)។**

លោកអ្នកប្រហែលជាចង់សួរថា តើព្រះជាម្ចាស់ពិតជាអាសធ្វើការដែលទ្រង់ប្រកាសថានឹងធ្វើមែនឬ? ខ្ញុំមិនអាចដឹងពីការនោះបានទេ។ រីឯព្រះបាទដាវីឌដែលទ្រង់

កត់ត្រាទុកសេចក្តីក្នុងជំពូកនេះមក ក៏ទ្រង់មិនអាចដឹងបានដែរ។ ព្រះបាទដាវីឌមានបន្ទូលថា “ការដឹងច្បាស់យ៉ាងនេះក៏អស្ចារ្យហួសល្បត់ដល់ទូលបង្គំ ហើយខ្ពស់ដល់ម្ល៉េះបានជាទូលបង្គំឈោងមិនដល់សោះ”។ តើការដឹងថា ព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ ធ្វើអោយលោកអ្នកមានទឹកចិត្តបែបណាដែរ? អ្នកខ្លះពេលដឹងថាព្រះជាម្ចាស់ជ្រាបអ្វីៗទាំងអស់ គេបែរជាខ្លាចដល់ព្រះជាម្ចាស់ ដូចខ្លាចមនុស្សពាលទៅវិញ។ ចំពោះព្រះហឫទ័យរបស់ព្រះជាម្ចាស់ ការដែលទ្រង់បើកអោយយើងដឹងថា ទ្រង់ជ្រាបគ្រប់ទាំងអស់ ទ្រង់ចង់អោយលោកអ្នកទទួលសេចក្តីកំសាន្តចិត្តពីព្រះអង្គ។ ព្រះអង្គបានផ្តល់សេចក្តីសង្គ្រោះដល់លោកអ្នក ពីព្រោះព្រះអង្គស្គាល់លោកអ្នកច្បាស់រួចទៅហើយ។ លោកអ្នកប្រហែលជាធ្លាប់ទុកចិត្តលើមនុស្សណាម្នាក់ ព្រមទាំងទទួលគេធ្វើជាមិត្តភក្តិយ៉ាងស្និទ្ធស្នាលរបស់លោកអ្នកផង។ ថ្ងៃមួយបុគ្គលនោះបានបែរជាធ្វើអោយលោកអ្នកមានការឈឺចាប់ និងមានការអស់សង្ឃឹមយ៉ាងខ្លាំង។ ពេលនោះលោកអ្នកនិយាយថា “ខ្ញុំពិតជាមិនបានស្គាល់បុគ្គលម្នាក់នេះអោយបានប្រាកដមែន”។ លោកអ្នកបងប្អូនអើយ ការដឹងថា ព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ ជាព្រះពរសម្រាប់យើង ពីព្រោះព្រះអង្គមិនដែលអោយលោកអ្នកខកចិត្តក្នុងការស្គាល់ព្រះអង្គទេ។ ព្រះអង្គទ្រង់ជ្រាបច្បាស់ពីលោកអ្នក បានជាព្រះអង្គផ្តល់សេចក្តីសង្គ្រោះដល់លោកអ្នកតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអង្គមិនដែលអោយនរណាម្នាក់ ដែលទុកចិត្តដល់ព្រះអង្គត្រូវខកចិត្តឡើយ។ ព្រះជាម្ចាស់ស្គាល់ច្បាស់ពីព្រះបាទដាវីឌ តែព្រះបាទដាវីឌបានធ្វើអោយទ្រង់មានការខកព្រះហឫទ័យ។ ប៉ុន្តែ ទោះព្រះអង្គមានការខកព្រះហឫទ័យយ៉ាងនោះក៏ដោយ ព្រះអង្គ

ស្គាល់ជំនឿរបស់ព្រះបាទដាវីឌ។ ទ្រង់ស្គាល់ទឹកចិត្តរបស់ព្រះបាទដាវីឌថា នៅមួយស្រទាប់ក្រោមជំនឿរបស់លោក មានជំនឿម្យ៉ាងដែលស្តេចអង្គនេះជឿដល់ព្រះជាម្ចាស់ថា ព្រះអង្គមិនដែលបណ្តោយអោយព្រះបាទដាវីឌទទួលការខកចិត្តទេ។ ព្រះជាម្ចាស់ស្គាល់លោកស៊ីម៉ូន-ពេត្រុស។ ព្រះអង្គស្គាល់យូដាសថា ពិតជាក្បត់ទ្រង់។ ចំណែកយើងរាល់គ្នាវិញ មិនបានដឹងប៉ុនមួយសរសៃសក់ពីអ្វីៗទាំងអស់ ដែលកំពុងមាននៅក្នុងចិត្តរបស់បុគ្គលម្នាក់ៗ។ ចំណែកព្រះជាម្ចាស់វិញ ទ្រង់ជ្រាបឥតមានសល់អ្វីទេ។ ព្រះអង្គមានព្រះរាជបុគ្គលិកលក្ខណៈប្រកបដោយសព្វញ្ញូញ្ញាណ។

## ព្រះជាម្ចាស់ជាព្រះប្រកបដោយសព្វវត្តមាន

តើលក្ខណៈព្រះជាម្ចាស់ដែលទ្រង់ប្រកបដោយសព្វវត្តមាន មានន័យយ៉ាងដូចម្តេច? មានន័យថា ទោះបីលោកអ្នកទៅដល់ទីណា លោកអ្នកមិនអាចគេចពីព្រះជាម្ចាស់បានទាល់តែសោះ។

> **[៧]តើទូលបង្គំនឹងទៅឯណា ឱ្យរួចពីព្រះវិញ្ញាណទ្រង់តើនឹងរត់ទៅ**
> **ឯណា ឱ្យរួចពីព្រះភក្ត្រទ្រង់ [៨]ទោះបើទូលបង្គំនឹងឡើងទៅឯស្ថាន**
> **សួគ៌ ក៏មានទ្រង់សណ្ឋិតនៅទីនោះ ទោះបើទូលបង្គំនឹងរៀប**
> **ដំណេកនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះក៏ឃើញមានទ្រង់**

**សណ្ឋិតនៅដែរ (ទំនុកដំកើង១៣៩:៧-៨)។**

ពាក្យថា "ស្ថានឃុំព្រលឹងមនុស្សស្លាប់" ជាភាសាហេព្រើរហៅថា ស្ហិអូល ដែលមិនមែនជាស្ថាននរកទេ។ ស្ថាននោះ គឺជាកន្លែងដែលព្រះជាម្ចាស់ឃុំព្រលឹងរបស់មនុស្សមានបាបទុកមួយកន្លែង រង់ចាំដល់ថ្ងៃជំនុំជំរះ។ ចំពោះគំនិតរបស់មនុស្សលោកយើង យើងមិនបានស្គាល់ថា ទីនោះស្ថិតនៅទីកន្លែងណាឡើយ។ ព្រះជាម្ចាស់ជ្រាបច្បាស់ថា តើសព្វថ្ងៃនេះ ស្ថានឃុំព្រលឹងមនុស្សស្លាប់នៅទីណា។ ទោះបីលោកអ្នកទៅលាក់ខ្លួននៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ព្រះជាម្ចាស់ជ្រាបពីទីនោះស្រាប់។

**ទោះបើទូលបង្គំនឹងយកស្លាបនៃបច្ចូសកាល ហោះទៅនៅឯទីបំផុតនៃសមុទ្រ (ទំនុកដំកើង១៣៩:៩)។**

បើលោកអ្នកយល់ថា អាចធ្វើដំណើរតាមអវកាសទៅពួនខ្លួននៅឯស្ថានព្រះចន្ទ នៅទីនោះលោកអ្នកក៏មិនអាចពួនពីព្រះជាម្ចាស់បានដែរ។ ព្រះអង្គគង់នៅទីនោះដែរ។ នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកអវកាសដែលបានឡើងទៅស្ថានព្រះចន្ទ មានបុរសបីនាក់ជាអ្នកកោតខ្លាចដល់ព្រះជាម្ចាស់។ កំពុងតែលោកទាំងនោះធ្វើដំណើរជុំវិញស្ថានព្រះចន្ទ លោកទាំងបីបាននាំគ្នាអានព្រះបន្ទូលលោកុប្បត្តិជំពូក១ នៅវេលាយប់ដែលគេធ្វើបុណ្យណូអែល។ បើលោកអ្នកចង់រត់អោយបាត់ពីព្រះជាម្ចាស់ លោកអ្នកមិន

អាចរត់គេចពីព្រះជាម្ចាស់ សូម្បីមួយវិនាទីចែកជាមួយម៉ឺនភាគក៏ដោយ។ ព្រះជាម្ចាស់ទ្រង់ប្រកបដោយសព្វវត្តមាន។

> **១០ គង់តែព្រហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ ហើយព្រះហស្ត**
> **ស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ ១១ បើទូលបង្គំថា សេចក្តីងងឹត នឹង**
> **គ្របបាំងទូលបង្គំជាប្រាកដ ហើយពន្លឺដែលភ្លឺនៅជុំវិញទូលបង្គំនឹង**
> **ត្រឡប់ជាយប់វិញ ១២ ដូច្នេះ ទាំងសេចក្តីងងឹតនោះឯង មិនលាក់**
> **ពីទ្រង់ឡើយ នោះទាំងយប់ក៏ភ្លឺដូចជាពេលថ្ងៃដែរ ឯសេចក្តីងងឹត**
> **នឹងពន្លឺភ្លឺ នោះស្មើគ្នានៅចំពោះទ្រង់ (ទំនុកដំកើង១៣៩:១០-១២)។**

បើព្រះជាម្ចាស់គង់នៅសព្វទីកន្លែង ទ្រង់ជ្រាបអ្វីទាំងអស់ តើលោកអ្នកចាំបាច់ត្រូវលន់តួអំពើបាបរបស់លោកអ្នកនៅចំពោះព្រះជាម្ចាស់ដែរឬទេ? លោកអ្នកចាំបាច់ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់នូវអំពើបាប ដែលលោកអ្នកបានប្រព្រឹត្តនៅចំពោះព្រះនេត្រព្រះអង្គ។ កាលលោកអ្នកកំពុងតែប្រព្រឹត្តអំពើបាប ព្រះជាម្ចាស់ជ្រាបច្បាស់ថា លោកអ្នកកំពុងប្រព្រឹត្តអំពើបាបនៅទីណា ព្រមទាំងកំពុងប្រព្រឹត្តអំពើបាបដោយវិធីណា។ ព្រះអង្គជ្រាបច្បាស់នៅកិរិយាប្រព្រឹត្តរបស់លោកអ្នក។ លោកអ្នកត្រូវសារភាពអំពើបាបរបស់លោកអ្នកនៅចំពោះព្រះអង្គ។ ការលន់តួអំពើបាបមានន័យថា លោកអ្នក

យល់ស្របជាមួយនឹងព្រះជាម្ចាស់ថា កិរិយាដែលលោកអ្នកបានប្រព្រឹត្ត ព្រះជាម្ចាស់រាប់ថា ជាអំពើបាប។ លោកអ្នកក៏យល់ស្របជាមួយនឹងព្រះជាម្ចាស់ថា កិរិយានោះជាអំពើបាបដែលលោកអ្នកបានប្រព្រឹត្តដែរ។ ការទូលថ្វាយដល់ព្រះជាម្ចាស់នៅកិរិយាដែលលោកអ្នកបានប្រព្រឹត្តដែលព្រះជាម្ចាស់រាប់ថា ជាអំពើបាប លោកអ្នកកំពុងលន់តួអំពើបាបរបស់លោកអ្នកនៅចំពោះព្រះជាម្ចាស់ហើយ។ ដូច្នេះ ដើម្បីលន់តួអំពើបាបរបស់លោកអ្នក លោកអ្នកចាំបាច់ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់នៅគ្រប់ទាំងរឿងអ្វីៗទាំងអស់។

**ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ (ទំនុកដំកើង១៣៩:១៣)។**

ចាប់ពីបុគ្គលម្នាក់ទំនៅក្នុងផ្ទៃម្តាយ បុគ្គលនោះមិនអាចរត់គេចពីព្រះជាម្ចាស់បានជាដាច់ខាត។ ខបន្ទាប់ទៅទៀតបញ្ជាក់ពីដំណើរនោះអោយកាន់តែច្បាស់ឡើង។

**ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ (ទំនុកដំកើង១៣៩:១៤)។**

ព្រះជាម្ចាស់គង់នៅសព្វទីកន្លែង។ ព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងកិរិយាប្រព្រឹត្តគ្រប់បែបយ៉ាងរបស់មនុស្សលោកគ្រប់រូប។ ព្រះអង្គផ្តោតព្រះហឫទ័យរបស់ទ្រង់លើបុគ្គលគ្រប់រូបរៀងរាល់ដង្ហើមចេញចូល។

> **[១៥] កាលទូលបង្គំកើតមាននៅទីកំបាំង ហើយបានសូនធ្វើបែបចំឡែកៗនៅទីទាបនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ [១៦] ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំក្នុងកាលដែលមិនទាន់មានរូបរាងនៅឡើយ ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់ គឺអស់ទាំងថ្ងៃអាយុ ដែលបានដំរូវឱ្យទូលបង្គំរស់នៅ ក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយនោះនៅឡើយ (ទំនុកដំកើង១៣៩:១៥-១៦)។**

មុននឹងរូបកាយរបស់ព្រះបាទដាវីឌ មានសណ្ឋានបែបណាមួយនៅក្នុងផ្ទៃម្តាយ ព្រះជាម្ចាស់រាប់ព្រះបាទដាវីឌថា ជាមនុស្សរួចទៅហើយ។ នៅក្នុងខណៈដែលមេជីវិតរបស់ម្តាយ និងឪពុកដាវីឌ ផ្តល់ជីវិតដល់ព្រះបាទដាវីឌ ព្រះជាម្ចាស់រាប់ព្រះបាទដាវីឌថា ជាមនុស្សក្នុងវិនាទីនោះតែម្តង។ រូបកាយរបស់ព្រះបាទដាវីឌមិនទាន់កើតចេញជារូបរាងនៅឡើយទេ។ ព្រះអង្គត្រូវសូនធ្វើព្រះបាទដាវីឌ អោយមានលក្ខណៈដូចជាអង្គ ព្រះបាទដាវីឌក្រោយពីបានប្រសូតចេញពីផ្ទៃម្តាយមក។ ដូច្នេះ តើមនុស្សចាប់ផ្តើម

មានជីវិតពីពេលណាមក? បើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលសម្តែងនៅក្នុងខខាងលើ បុគ្គលម្នាក់រាប់ថា ជាមនុស្សក្នុងខណៈដែលបុគ្គលម្នាក់ចាប់បដិសន្ធិនៅក្នុងផ្ទៃម្តាយ ទោះរូបកាយមិនទាន់មានជារូបរាងនៅឡើយក៏ដោយ។

ចំណុចខាងលើ មានសារៈសំខាន់ខ្លាំងណាស់ទាក់ទងនឹងវិបត្តពន្លូតកូន។ បើព្រះជាម្ចាស់រាប់ថា ជីវិតរបស់មនុស្សចាប់ផ្តើមពេលបុគ្គលម្នាក់នោះចាប់ផ្តើមបដិសន្ធិនៅក្នុងផ្ទៃម្តាយ តើការពន្លូតកូនមានទោសស្មើនឹងអ្វី? ការពន្លូតកូនមានទោសស្មើនឹងសម្លាប់មនុស្សពេញវ័យម្នាក់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្តែងយ៉ាងច្បាស់ជាងពន្លឺថ្ងៃទៅទៀត។ នៅក្នុងខណៈដែលព្រះបាទដាវីឌចាប់ទំផ្ទៃម្តាយ រូបកាយរបស់លោកមិនទាន់មានរូបរាងនៅឡើយទេ។ ពេលនោះព្រះជាម្ចាស់រាប់ព្រះបាទដាវីឌថា ជាមនុស្សរួចទៅហើយ។ ដូច្នេះ ការពន្លូតកូនមានទោសស្មើនឹងសម្លាប់ជីវិតមនុស្សពេញវ័យម្នាក់។

ប៉ុន្តែ ចុះបើកូននោះចាប់បដិសន្ធិនៅក្នុងផ្ទៃម្តាយ ហើយគ្រូពេទ្យជ្រាបច្បាស់ថា កូននោះសម្លាប់ម្តាយខ្លួនចោល តើការពន្លូតកូនអាចធ្វើបានដែរឬទេ? ក្នុងករណីនេះការពន្លូតកូនអាចធ្វើទៅបាន។ ប៉ុន្តែ ការពន្លូតកូនដែលធ្វើឡើងដោយមូលហេតុខ្មាសគេ ឬមិនព្រមទទួលខុសត្រូវពីសំណាក់មនុស្សស្រីឬមនុស្សប្រុស រាប់ថាជាឧក្រិដ្ឋកម្មយ៉ាងសាហាវយង់ឃ្នងជាទីបំផុត។ ខ្ញុំហ៊ានវិនិច្ឆ័យយ៉ាងដូច្នេះ ពីព្រោះមិនមែនជាគំនិតរបស់ខ្ញុំផ្ទាល់ទេ ព្រះបាទដាវីឌបានកត់ត្រារឿងនេះទុកមក។ មិនតែប៉ុណ្ណោះ គំនិតនោះមកពីព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដែលទ្រង់បានបណ្តាលអោយព្រះបាទដាវីឌកត់ត្រារឿងនោះទុកមកសម្រាប់យើង។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្តល់ចម្លើយគ្រប់វិស័យ

សម្រាប់ជីវិតរស់នៅ។ ជនណាដែលបកស្រាយព្រះបន្ទូលត្រឹមត្រូវតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជននោះពិតជាត្រូវគេបកស្បែកទាំងរស់ ទោះក្នុងចំណោមគ្រីស្ទបរិស័ទ ឬក្នុងចំណោមអ្នកមិនជឿក្តី។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាទស្សនៈនៃជីវិតដែលព្រះជាម្ចាស់មានសម្រាប់មនុស្សលោក។

## ព្រះជាម្ចាស់ជាព្រះប្រកបដោយសព្វានុភាព

> **[១៧] ឱព្រះអង្គអើយ ព្រះដំរិះរបស់ទ្រង់មានដំឡៃវិសេស ដល់ទូលបង្គំណាស់ហ្ន៎ ក៏មានចំនួនច្រើនណាស់ផង [១៨] បើសិនជាទូលបង្គំនឹងខំរាប់ចំនួន នោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត កាលណាទូលបង្គំភ្ញាក់ឡើង នោះទូលបង្គំនៅជាមួយនឹងទ្រង់នៅឡើយ (ទំនុកដំកើង១៣៩:១៧-១៨)។**

ព្រះជាម្ចាស់ស្រឡាញ់ដល់មនុស្សលោកខ្លាំងណាស់។ ទោះបីព្រះអង្គប្រកបដោយសព្វានុភាព ពោលគឺព្រះអង្គមានចេស្តាអាចធ្វើអ្វីបានទាំងអស់ក្តី ព្រះអង្គស្រឡាញ់ដល់មនុស្សលោក។ ទ្រង់ស្រឡាញ់ដល់មនុស្សលោក បានជាព្រះអង្គធ្វើអ្វីទាំងអស់ ដើម្បីស្រោចស្រង់មនុស្សលោកដោយចេស្តារបស់ទ្រង់ ដែលទ្រង់អាចសម្រេចធ្វើគ្រប់ទាំងអស់បាន។

**ឱព្រះអង្គអើយ ទ្រង់នឹងប្រហារពួកមនុស្សអាក្រក់ជាមិនខាន នែពួកមនុស្សដែលកំចាយឈាមអើយ ចូរថយចេញពីអញទៅ (ទំនុកដំកើង១៣៩:១៩)។**

ទោះបីព្រះអង្គមានគ្រប់ទាំងព្រះចេស្តា ទោះបីព្រះអង្គជំនុំជំរះដល់មនុស្សអាក្រក់ ព្រះអង្គយកព្រះហឫទ័យផ្ទៀងស្តាប់សេចក្តីអធិស្ឋានរបស់យើង។ សូមថ្វាយបទសរសើរដល់ព្រះជាម្ចាស់ ព្រោះទ្រង់ប្រកបដោយសព្វញ្ញុញ្ញាណ ប្រកបដោយសព្វានុភាព និងប្រកបដោយសព្វវត្តមាន។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ “ដើរជាមួយនឹងព្រះ ពិតជាប្រទះជាមួយនឹងព្រះយេស៊ូវជាមិនខាន!”